# ដឹងពីសិទ្ធិរបស់អ្នក

ក្រុមធ្វើការងារនៃ
អន្តរទីភ្នាក់ងារសហព័ន្ធ
លើភាពចេះភាសាអង់គ្លេសម
ានកំណត់



ប្រសិនបើអ្នកជឿជាក់ថា អ្នកបានជួបប្រទះនឹងការរើសអើងពីដើមកំណើតជាតិសាសន៍ រឺចង់បានពត៌មានបន្ថែម សូមទាក់ទង:

អ្នកក៏អាចនិយាយជាមួយអ្នកគ្រប់គ្រង អំពីមនុស្សដែលអ្នកគិតថាមានការរើសអើងចំពោះអ្នក។ អ្នកក៏អាចនិយាយផងដែរ ជាមួយក្រុមសហគមន៍មួយដែលធ្វើការលើបញ្ហាសិទ្ធិស៊ីវិល។

រួមគ្នា យើងអាចជួយមនុស្សអោយទទួលអត្ថប្រយោជន៍ និងសេវាផ្សេងៗដែលពួកគេត្រូវការ នៅក្នុងរបៀបផ្សេងៗដែលពួកគេអាចយល់បាន។

ឧបត្ថម្ភដោយក្រសួងកសិកម្មសហរដ្ឋអាមេរិក
ក្រសួងសុខាភិបាលនិងសេវាមនុស្សសហរដ្ឋអាមេរិក
និង ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។

តើអ្នកមានបញ្ហាជាមួយភាសាអង់គ្លេសដែររឺទេ? តើអ្នកមិនអាចអាន សរសេរ រឺយល់ភាសាអង់គ្លេសបានល្អទេរឺ? ប្រសិនបើដូច្នោះ អ្នកគឺជាអ្នកចេះភាសាអង់គ្លេសនៅមានកំណត់ **[Limited English Proficient (LEP)]** ។

ទីភ្នាក់ងារសហព័ន្ធ និង អង្គការនានា ដែលទទួលលុយពីរដ្ឋាភិបាលសហព័ន្ធ ត្រូវតែចាត់វិធានការណ៍ សមស្រប ដើម្បីជួយប្រជាពលរដ្ឋដែលមានបញ្ហា ផ្នែកភាសាអង់គ្លេស។

ជនកាល នៅពេលដែលទីភាក់ងាររដ្ឋាភិបាលមយ

Cambodia

The contents of this guidance document do not have the force and effect of law and are not meant to bind the public in any way. This document is intended only to provide clarity to the public regarding existing requirements under the law or agency policies.

# បើអ្នកត្រូវបានគេប្រព្រឹត្តមិនត្រឹមត្រូវ ពីព្រោះអ្នកជា LEP នោះវាប្រហែលជាការរើសអើងដើមកំណើតហើយ។



មានច្បាប់សហព័ន្ធមួយ ដែលការពារនូវសិទ្ធិស៊ីវិលរបស់អ្នក។ ច្បាប់នោះត្រូវបានអោយឈ្មោះថា ***"Title VI"*** នៃច្បាប់សិទ្ធិស៊ីវិលនៃឆ្នាំ ***1964.***

## ឧទាហរណ៏នៃការរើសអើងដែលអាចមាន:

**1** អអ្នក និងមនុស្សជាច្រើន ដែលរស់នៅក្នុងតំបន់របស់អ្នក និយាយភាសាខ្មែរ ហើយក៏ទៅមន្ទីរពេទ្យជាញឹកញយសំរាប់ការព្យាបាលជាអាសន្ន។ មន្ទីរពេទ្យមិនយល់អ្នកជំងឺ **LEP** ទាំងនោះឡើយ។ ភាគច្រើននៃអ្នកជំងឺជាជនជាតិខ្មែរ មិនយល់ពីអ្វីដែលមន្ទីរពេទ្យប្រាប់គេអំពីការថែទាំសុខភាពរបស់គេទេ។

**2** អ្នក ទូរស័ព្ទទៅលេខ **911** ដើម្បីរាយការណ៍ពីបទឧក្រិដ្ឋមួយ។ អ្នកដែលទទួលទូរស័ព្ទ មិនយល់ពីអ្នក ហើយមិនអាចជួយអ្នក បាន។

**3** សាលារៀនរបស់កូនរបស់អ្នកផ្ញើរនូវពត៏មាន រឺសេចក្ដីជូនដំណឹងមួយដល់អ្នកជាភាសាអង់គ្លេស។ សាលា ដឹងថាអ្នកនិយាយតែភាសាអេស្ប៉ាញ៉ុលប៉ុណ្ណោះ។ សាលាបដិសេធមិនព្រមផ្ដល់ពត៏មានដល់អ្នកជាភាសាអេស្ប៉ាញ៉ុល ហើយផ្ញុយទៅវិញ ស្នើរអោយកូនរបស់អ្នកបកប្រែពត៏មាននោះអោយអ្នក។

**4** អ្នក ព្យាយាមដាក់ពាក្យសុំហ្វូតស្ដែម។ ពាក្យសុំនោះសរសេរជាភាសាអង់គ្លេស។ អ្នកមិនយល់ពីពាក្យសុំនោះទេ។ បុគ្គលិកការិយាល័យហ្វូតស្ដែម ប្រាប់អ្នកអោយត្រឡប់មកវិញម្ដងទៀតដោយនាំអ្នកបកប្រែដោយផ្ទាល់ខ្លួនរបស់អ្នកមកជាមួយ។

## ឧទាហរណ៏នៃការអនុវត្តន៏ល:

**1** មន្ទីរពេទ្យដឹងថាមានមនុស្សច្រើនណាស់ ដែលមិនអាច យល់ភាសាអង់គ្លេស ហើយនិយាយភាសាខ្មែរ ដែលរស់នៅក្នុងតំបន់របស់អ្នក។ មន្ទីរពេទ្យមានអ្នកបកប្រែដែលប្រុងខ្លួចជាស្រេច ហើយអាចជួយអ្នកបាន នៅពេលអ្នកទៅមន្ទីរពេទ្យ សំរាប់ការថែទាំព្យាបាលនៅពេលអាសន្ន។

**2** អ្នក ទូរស័ព្ទទៅ **911** ដើម្បីរាយការណ៍ពីបទឧក្រិដ្ឋមួយ។ អ្នកដែលទទួលទូរស័ព្ទ ភ្ជាប់អ្នកភ្លាមទៅកាន់អ្នកបកប្រែដែលអាចជួយអ្នកបាន។

**3** សាសារៀនរបស់កូនរបស់អ្នកមានឪពុកម្ដាយនិយាយភាសាអេស្ប៉ាញ៉ុលជាច្រើននាក់។ សាលាដឹងថាអ្នក និយាយបានតែភាសាអេស្ប៉ាញ៉ុលតែប៉ុណ្ណោះ។ អ្នកគួរ តែទទួលពត៏មានសំខាន់ៗ រឺសេចក្ដីជូនដំណឹងជា ភាសាអេស្ប៉ាញ៉ុល។

**4** ការិយាល័យហ្វូតស្ដែម មានអ្នកបកប្រែ រឺទាក់ទងអ្នកបកប្រែតាមទូរស័ព្ទអោយជួយអ្នក។ ពាក្យសុំជាភាសារបស់អ្នកត្រូវបានផ្ដល់អោយអ្នក។